# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាជាមួយអដ្ឋិធាតុរបស់សន្ត លូវីស និងសន្តី ហ្សេលី ម៉ាតាំង
# ផ្សារតូច ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៩
## គ្រួសារដែលទទួលស្គាល់ថាព្រះជាម្ចាស់ជាព្រះបិតាដែលស្រឡាញ់យើងបំផុត

**អត្ថបទទី១៖ បេនស៊ីរ៉ាក ៣,១៧-១៨.២០.២៨-២៩**

ពេលកូនមានបុណ្យស័ក្តិកាន់តែខ្ពស់យ៉ាងណា ត្រូវតែដាក់ខ្លួនឲ្យកាន់តែទាបយ៉ាងនោះដែរ ហើយព្រះអម្ចាស់នឹងប្រោសប្រណីដល់កូន។ បសរ ៣,១៨

**អត្ថបទទី២៖ ហេប្រឺ ១២,១៨-១៩.២២-២៤**

បងប្អូនចូលមកជិតព្រះជាម្ចាស់ ដែលវិនិច្ឆ័យមនុស្សទាំងអស់ និងចូលមកជិតវិញ្ញាណក្ខ័ន្ធអ្នកសុចរិតដែលបានគ្រប់លក្ខណៈ។ ហាប ១២,២៣

**ដំណឹងល្អ៖ លូកា ១៤,១.៧-១៤**

បើមានគេអញ្ជើញអ្នកទៅជប់លៀង ក្នុងពិធីមង្គលការណាមួយ សុំកុំទៅអង្គុយកន្លែងដែលគេបម្រុងទុកសម្រាប់ភ្ញៀវកិត្តិយស ក្រែងលោគេបានអញ្ជើញភ្ញៀវម្នាក់ទៀត មានឋានៈខ្ពស់ជាងអ្នក។ លក ១៤,៨

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ ជាថ្ងៃមហាឱឡារិកណែនាំឲ្យព្រះសហគមន៍យើងមានអំណរសប្បាយ ទទួលស្វាគមន៍ធាតុរបស់សន្ត លូវីស និងសន្តី ហ្សេលី។ ពីថ្ងៃចន្ទ យើងបានទៅមណ្ឌលសកម្មភាពមួយចំនួនហើយ ខ្ញុំរំលឹកខ្លីៗអំពីប្រវត្តិសាស្ត្រទាំងពីរនាក់ លូវីស និងហ្សេលី ពេលនៅក្មេងគេចង់ធ្វើជាបូជាចារ្យនិងបងស្រី ប៉ុន្តែគេមិនអាចទៅមុខនៅក្នុងដំណើរធ្វើជាបូជាចារ្យនិងបងស្រី នៅថ្ងៃមួយគេបានជួបគ្នាលើស្ពានមួយ ពេលគេឃើញគ្នាទៅវិញទៅមកគេយល់ថា គេត្រូវតែមានជីវិតជាប្តីប្រពន្ធពីពេលនេះតទៅ។ ដូច្នេះ បីខែក្រោយមកគេរៀបការហើយមានកូន៩នាក់ នៅក្នុងកូន៩នាក់មាន៤នាក់បានទទួលមរណភាពនៅពេលគេនៅតូចៗ នៅសល់កូនស្រី៥នាក់ កូនស្រីពៅគេគឺសន្តីតេរេសានៃព្រះកុមារយេស៊ូ។ កូនស្រីទាំង៥នាក់ បានទៅជាដូនជី ហ្សេលីគាត់បានទទួលមរណភាពនៅពេលគាត់អាយុតែ៤៦ឆ្នាំ នៅពេលនោះសន្តីតេរេសាមានអាយុតែ៤ឆ្នាំ ដោយសារមហារីកសុដន់។ លូវីស បានយកចិត្តទុកដាក់ថែរក្សាកូនៗរបស់គាត់ រហូតដល់គាត់ទទួលមរណភាពនៅអាយុ៧១ឆ្នាំ។ ព្រះសហគមន៍បានទទួលស្គាល់ទាំងពីរនាក់ ជាអ្នកពោរពេញដោយសុភមង្គលនៅឆ្នាំ២០០៨ ដោយសម្តេចប៉ាបបេណេឌីតូ និងនៅឆ្នាំ២០១៥នេះព្រះសហគមន៍ទទួលស្គាល់ ជាលើកទី១យើងមានប្តីប្រពន្ធដែលព្រះសហគមន៍ទទួលស្គាល់ ជាសន្តសន្តីបុគ្គល។

ដូច្នេះ ថ្ងៃនេះសម្រាប់ព្រះសហគមន៍យើង យើងមានបីសប្ដាហ៍សម្រាប់ភូមិភាគភ្នំពេញ បាត់ដំបង កំពង់ចាម ជាឱកាសមួយយ៉ាងពិសេសនៅក្នុងឆ្នាំនៃគ្រួសារ ដើម្បីធ្វើដំណើរជាមួយគ្រួសារដ៏វិសុទ្ធនេះ ដើម្បីសុំព្រះពរសម្រាប់គ្រួសាររបស់យើង ដើម្បីទទួលកម្លាំងថ្មីពីគ្រួសារដែលជាគ្រួសារដែលពោរពេញដោយសុភមង្គល។ ណែនាំឲ្យយើងអាចគិតពីជីវិតរបស់យើង គិតអំពីជីវិតយើងជាគ្រួសារបច្ចុប្បន្ននេះ ជីវិតយើងជាគ្រួសារនៅថ្ងៃអនាគត ដើម្បីទទួលព្រះពរពីព្រះជាម្ចាស់ ដោយយកទាំងពីរនាក់ជាគំរូ ដើម្បីទៅមុខនៅក្នុងជីវិតរបស់យើងជាប្ដីប្រពន្ធ ជាកូន ជាគ្រួសារ ដើម្បីរកឃើញគ្រួសារដ៏វិសុទ្ធនៅក្នុងជីវិតរបស់យើង។ សម្រាប់គ្រួសារនេះ **តើព្រះជាម្ចាស់ជានរណា?** ព្រះជាម្ចាស់ជាអ្នកណាសម្រាប់សន្ដលូវីស និងសន្ដី ហ្សេលី និងក្រុមគ្រួសារទាំងមូល អត្ថបទទី២ថ្ងៃនេះ ដូចជាភ្ជាប់នឹងជីវិតទាំងពីរនាក់ "**កុំឲ្យយើងទៅជិតភ្នំមួយដែលនាំឲ្យយើងភ័យខ្លាច ដើម្បីជួបជាមួយព្រះជាម្ចាស់**"។ គ្រួសារនេះអស់មួយជីវិត បានយកចិត្តទុកដាក់រកព្រះជាម្ចាស់ ជួបជាមួយព្រះជាម្ចាស់ គេបានយល់ថាបើគេចង់រកព្រះជាម្ចាស់មិនអាចទៅរកនៅក្នុងភ្នំមួយដែលមានភ្លើងឆេះណែនាំឲ្យគេភ័យខ្លាច។ ផ្ទុយទៅវិញ ប្រសិនបើគេចង់រកព្រះជាម្ចាស់គេត្រូវការទៅដល់ភ្នំនៃទីក្រុងយេរូសាឡឹមនៅស្ថានបរមសុខ ដែលប្រមូលមនុស្សដែលមានឈ្មោះកត់ទុកនៅស្ថានបរមសុខ កំពុងជួបជុំគ្នាយ៉ាងជិតស្និទ្ធ។ គ្រួសារនេះ ជាមួយកូនស្រីសន្ដីតេរេសា បានទៅស្ថានបរមសុខកំពុងជួបជុំគ្នា។ បន្ដទៀត "**បងប្អូនចូលមកជិតព្រះជាម្ចាស់ ដែលវិនិច្ឆ័យមនុស្សទាំងអស់ និងចូលមកជិតវិញ្ញាណក្ខន្ធអ្នកសុចរិតដែលបានគ្រប់លក្ខណៈ**" យើងមានសុភមង្គលហើយថ្ងៃនេះ ដោយសារយើងភ្ជាប់ជាមួយវិញ្ញាណក្ខន្ធនៃមនុស្សដែលមានគ្រប់លក្ខណៈ គឺសន្ដ លូវីស និងសន្ដី ហ្សេលី។

ព្រះសហគមន៍កាតូលិកនៅផ្សារតូចថ្ងៃនេះ ពោរពេញដោយសុភមង្គលដូចលោកប៉ូលបាននិយាយ "**បងប្អូនសូមចូលមកជិតវិញ្ញាណក្ខន្ធអ្នកសុចរិតដែលបានគ្រប់លក្ខណៈ**" នេះជាការអស្ចារ្យសម្រាប់ជីវិតរបស់យើង។ បន្ដទៀត "**បងប្អូនចូលមកជិតព្រះយេស៊ូដែលជាស្ពាននៃសម្ពន្ធមេត្រីថ្មី**" នេះជាអ្វីដែលសន្ដីតេរេសាបានយល់យ៉ាងច្បាស់ នៅពេលសន្ដីតេរេសាបាននឹកឃើញ "**ខ្ញុំធ្វើដូចម្ដេចដើម្បីចូលស្ថានបរមសុខ? ខ្ញុំធ្វើដូចម្ដេចដើម្បីទទួលជីវិតអស់កល្បជានិច្ច?**"។ សម័យសន្ដីតេរេសា គេចាប់ផ្ដើមមានផ្សារទំនើបដែលមានជណ្ដើរយន្ដ ហើយគាត់នឹកឃើញ "**ប្រសិនបើខ្ញុំចង់ឡើងស្ថានបរមសុខ ខ្ញុំត្រូវការជិះជណ្ដើរយន្ដដែលណែនាំឲ្យខ្ញុំទៅលឿន ប្រសិនបើខ្ញុំជិះតាមជណ្ដើរធម្មតា អស់កម្លាំងនិងណែនាំឲ្យខ្ញុំហត់និងបែកញើសទៀត**" គាត់រកឃើញជណ្ដើរយន្ដនេះគឺព្រះយេស៊ូផ្ទាល់។ គាត់យល់ថា "**ប្រសិនបើខ្ញុំទុកឲ្យព្រះយេស៊ូចាប់ដៃខ្ញុំដើម្បីណែនាំឲ្យខ្ញុំឡើងស្ថានបរមសុខភ្លាមៗស្រួលជាងគេ**" នេះជាផ្លូវដ៏តូចតាចដែលសន្ដីតេរេសាបានរកឃើញ។ ថ្ងៃនេះ

យើងបានស្តាប់ "**បងប្អូនចូលមកជិតព្រះយេស៊ូ ដែលជាស្ពាននៃសម្ពន្ធមេត្រីថ្មី**" អាចនិយាយបានថាជាជណ្តើរយន្តនៅក្នុងភាពទំនើបបច្ចុប្បន្ននេះ។ ថ្ងៃនេះ យើងត្រូវតែគិតពិចារណា យើងចង់ឡើងស្ថានបរមសុខដើម្បីជួបព្រះជាម្ចាស់ ប៉ុន្តែព្រះជាម្ចាស់ជានរណាសម្រាប់យើងជាគ្រីស្តបរិស័ទ? យើងបានស្តាប់នៅក្នុងគម្ពីរដំណឹងល្អថា "**អ្នកណាលើកតម្កើងខ្លួនអ្នកនោះនឹងត្រូវគេបន្ទាបចុះ រីឯអ្នកដែលបន្ទាបខ្លួននឹងត្រូវគេលើកតម្កើង**" ព្រះយេស៊ូកំពុងបង្ហាញអំពីរបៀបដែលយើងត្រូវរស់នៅ។ កុំឲ្យយើងលើកតម្កើងផ្ទាល់ កុំឲ្យយើងអង្គុយលើបល្ល័ង្គ កុំឲ្យយើងអង្គុយលើគេ ផ្ទុយទៅវិញឲ្យយើងសុខចិត្តបន្ទាបខ្លួនដោយដឹងថានៅពេលហ្នឹង ព្រះជាម្ចាស់ចាត់យើងឲ្យទទួលសិរីរុងរឿងរួមជាមួយព្រះជាម្ចាស់។ នៅពេលព្រះយេស៊ូនិយាយដូចនេះ ព្រះយេស៊ូកំពុងបង្ហាញព្រះអង្គផ្ទាល់ គឺព្រះជាម្ចាស់ចាប់កំណើតជាមនុស្សនៅថ្ងៃបុណ្យព្រះយេស៊ូប្រសូត។ ព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់បំផុត នៅស្ថានបរមសុខចុះនៅលើផែនដីដើម្បីធ្វើជាទារកមួយរូបណែនាំឲ្យក្រុមទេវទូត ណែនាំឲ្យមនុស្សទាំងឡាយមកកោតសរសើរទារកនេះ គឺព្រះជាម្ចាស់ដែលខ្ពង់ខ្ពស់បំផុត ចាប់កំណើតជាមនុស្សតាមរយៈទារកមួយ មិនអាចបន្ទាបខ្លួនលើសពីនេះបានទេ។

នៅពេលយើងស្តាប់គម្ពីរថ្ងៃនេះ យើងចាប់ផ្តើមចូលដើម្បីយល់ថាព្រះជាម្ចាស់ជានរណា? ព្រះជាម្ចាស់ណែនាំឲ្យយើងយល់ថា ដើម្បីទទួលសិរីរុងរឿងរួមជាមួយព្រះអង្គឲ្យយើងដាក់ខ្លួន កុំឲ្យយើងអង្គុយលើបល្ល័ង្គ ព្រះជាម្ចាស់ដែលបានចាប់កំណើតជាមនុស្ស ព្រះជាម្ចាស់ដែលបានសោយទិវង្គតនៅលើព្រះឈើឆ្កាង ប៉ុន្តែទីបញ្ចប់ព្រះជាម្ចាស់ដែលណែនាំឲ្យព្រះយេស៊ូមានព្រះជន្មថ្មីដ៏រុងរឿង។ នៅក្នុងគម្ពីរដំណឹងល្អថ្ងៃនេះ "**អ្នកនឹងមានសុភមង្គលជាមិនខាន ត្បិតអ្នកនោះមិនអាចតបស្នងអ្នកបានឡើយ គឺព្រះជាម្ចាស់ទេនឹងតបស្នងជូនអ្នកនៅពេលមនុស្សសុចរិតរស់ឡើងវិញ**" តាមពិតព្រះយេស៊ូកំពុងនិយាយថា អ្នកដែលមានសុភមង្គលគឺអ្នកដែលទទួលនិងអញ្ជើញអ្នកតូចតាចដោយដឹងថា អ្នកខ្វាក់ អ្នកខ្វិន អ្នកក្រីក្រ នៅពេលយើងអញ្ជើញគេឲ្យញុំាបាយជាមួយយើង គេមិនអាចតបស្នងយើងវិញបានទេ យើងអញ្ជើញគេប៉ុន្តែគេមិនអញ្ជើញយើងវិញទេ។ ជួនកាលយើងចូលចិត្តអញ្ជើញមិត្តភ័ក្ត ដោយដឹងថាពេលក្រោយគេអញ្ជើញយើងវិញ ប៉ុន្តែព្រះយេស៊ូណែនាំឲ្យយើងមានរបៀបថ្មី កុំឲ្យយើងសង្ឃឹមឲ្យគេសងគុណយើងវិញ។ នេះជារបៀបព្រះជាម្ចាស់ដែរ នៅពេលព្រះយេស៊ូបង្ហាញអំពីព្រះហឫទ័យស្រឡាញ់របស់ព្រះបិតាចំពោះអ្នកតូចតាច ចំពោះអ្នកដែលគ្មានទីពឹង គ្មានសេចក្តីសង្ឃឹម។ ព្រះជាម្ចាស់នៅជាមួយគេមុនគេបង្អស់ ជាមួយកូនក្មេង ជាមួយមនុស្សដែលអត់មានសង្ឃឹមនៅក្នុងជីវិត យើងបានឃើញនៅក្នុងព្រះយេស៊ូ។ ជីវិតរបស់ព្រះយេស៊ូគឺនៅជាមួយអ្នកតូចតាច ជាមួយអ្នកដែលគ្មានសង្ឃឹម ណែនាំឲ្យគេមានជីវិតថ្មីជារៀងរាល់ថ្ងៃដោយដឹងថា ព្រះជាម្ចាស់មិនចាំឲ្យគេសងគុណ ឲ្យគេដឹង

គុណ ប៉ុន្តែព្រះជាម្ចាស់ប្រទានឲ្យគេពោរពេញដោយសេចក្ដីសុខនៅក្នុងសេចក្ដីស្រឡាញ់របស់ព្រះអង្គ។ នេះជារបៀបរបស់ព្រះជាម្ចាស់ នេះជារបៀបដែលយើងត្រូវដើរតាម និងជារបៀបដែលសន្តិ លូវីស និងសន្តី ហ្សេលី បានរស់នៅ។

ជីវិតរបស់សន្ត លូវីស និងសន្តី ហ្សេលី រស់នៅដោយបង្ហាញអំពីវត្តមានរបស់ព្រះជាម្ចាស់ ជីវិតរបស់គេមិនមែនជាសៀវភៅដែលនិយាយពន្យល់អំពីទេវវិទ្យាទេ ប៉ុន្តែជីវិតរបស់គេជាបទពិសោធន៍យ៉ាងជាក់ស្ដែងអំពីព្រះជាម្ចាស់។ ព្រះជាម្ចាស់ ដែលពោរពេញដោយសេចក្ដីស្រឡាញ់ ព្រះជាម្ចាស់ដែលគង់នៅជាមួយយើងជាប្រចាំ។ នៅពេល ហ្សេលី មានផ្ទៃពោះគាត់និយាយថា "**ខ្ញុំអត់ដែលភ័យអ្វីសោះដោយសារខ្ញុំដឹងថាព្រះជាម្ចាស់គង់នៅ**" នៅក្នុងប៉ុន្មានឆ្នាំដែលគេបានរស់នៅជាប្ដីប្រពន្ធ ហ្សេលី មានផ្ទៃពោះ៩ដងដែលមាន៤នាក់បានស្លាប់។ ដូច្នេះ គាត់មានបទពិសោធន៍យ៉ាងច្រើន ប៉ុន្តែគាត់ដឹងថាគាត់មិនខ្លាចអ្វីទេ ពេលគាត់មានផ្ទៃពោះគាត់ដឹងថាព្រះជាម្ចាស់គង់នៅជាមួយគាត់។ នៅពេលកូនគាត់ស្លាប់ទាំងបួននាក់ មានខ្លះគេនិយាយទៅគាត់ថា ព្រះជាម្ចាស់អាណិតឃើញមានកូនច្រើនពិបាកចិញ្ចឹម ដូច្នេះព្រះជាម្ចាស់បានយកវិញខ្លះទៅស្ថានបរមសុខភ្លាមៗ កុំឲ្យអស់កម្លាំងដើម្បីចិញ្ចឹមប្រាំបួននាក់។ ប៉ុន្តែ ហ្សេលី និយាយថា នេះមិនមែនរបៀបព្រះជាម្ចាស់ទេ ប៉ុន្តែខ្ញុំដឹងថាព្រះជាម្ចាស់មានព្រះហឫទ័យស្រឡាញ់ខ្ញុំជានិច្ច ដូច្នេះប្រសិនបើព្រះជាម្ចាស់ត្រូវតែទទួលកូនរបស់ខ្ញុំឆាប់ៗ ខ្ញុំមិនត្រូវការសុំការអនុញ្ញាតពីព្រះជាម្ចាស់ទេ ធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់នឹងខ្ញុំទទួលដែរ។

សន្ត លូវីស និងសន្តី ហ្សេលី គេស្គាល់ព្រះជាម្ចាស់របៀបណា? មិនមែនដោយសារគេអានសៀវភៅ មិនមែនដោយសារគេទៅស្ដាប់ធម្មទេសនា មិនមែនដោយសារគេចូលនៅក្នុងសិក្ខាសាលាដើម្បីពន្យល់ព្រះជាម្ចាស់ជាអ្នកណា? គេស្គាល់ព្រះជាម្ចាស់ដោយសារគេមានបទពិសោធន៍យ៉ាងជាក់ស្ដែង ជារៀងរាល់ថ្ងៃម៉ោង៥កន្លះគេចូលអភិបូជា រាល់ពេលព្រឹកភ្ញាក់ពីដេកម៉ោង៥រៀបចំខ្លួនឲ្យកូនៗទាំងអស់ ដើរទៅអភិបូជាជាមួយកម្មករ។ ម្យ៉ាងទៀត ដើម្បីមានបទពិសោធន៍អំពីព្រះជាម្ចាស់ គេចូលគ្រប់សកម្មភាពរបស់ព្រះសហគមន៍ ពេលមានអធិដ្ឋានពេលយប់គេចូល ពេលមានតាំងព្រះកាយគេចូល ពេលមានគណៈកម្មការសង្គហៈគេចូល។ ពេលគេដូរទៅរស់នៅពីទីក្រុងអាឡង់ស្សុងទៅទីក្រុងលីហ្សឺ នៅទីក្រុងចាស់ដែលគេរស់នៅមានអធិដ្ឋានមួយយប់ ហើយនៅទីក្រុងថ្មីដែលគេរស់នៅគ្មានកម្មវិធីអធិដ្ឋានពេញមួយយប់ទេ ដូច្នេះទាំងពីរនាក់គេបានបង្កើតដើម្បីឲ្យព្រះសហគមន៍មានទំលាប់អធិដ្ឋាន តាំងព្រះកាយ នឹកឃើញដល់ព្រះជាម្ចាស់។ មួយទៀត ដើម្បីស្គាល់ព្រះជាម្ចាស់គេមើលឃើញយើងមានកូនប្រាំនាក់ យើងចង់ឲ្យកូនយើងស្គាល់ព្រះជាម្ចាស់យ៉ាងជិតស្និទ្ធ។ ព្រឹកឡើង នៅពេលគេភ្ញាក់ពីដេកគេណែនាំឲ្យកូនៗ

ជំរាបសួរព្រះយេស៊ូភ្លាមៗ ពេលគេកំពុងពាក់អាវឲ្យកូនៗគេនិទានរឿងព្រះយេស៊ូដើម្បីឲ្យកូនៗស្តាប់ ស្គាល់ព្រះយេស៊ូ ស្គាល់ព្រះនាងម៉ារី ស្គាល់លោកយ៉ូសែប ស្គាល់សន្តនិងសន្តីទាំងឡាយ និងក្រោយមកគេមានអធិដ្ឋានខ្លីៗ។ មុនចូលដេក គ្រួសាររួមគ្នាដើម្បីអធិដ្ឋានជាលក្ខណៈគ្រួសារ ដើម្បីអរព្រះគុណព្រះជាម្ចាស់សម្រាប់មួយថ្ងៃ សុំឲ្យព្រះជាម្ចាស់ប្រទានពរដើម្បីដេកយ៉ាងស្រួល ដើម្បីមានសុបិនល្អរួមជាមួយសន្តយ៉ូសែបនិងព្រះនាងម៉ារីជាមួយព្រះយេស៊ូ។

អាចនិយាយថា សម្រាប់គ្រួសារនេះវត្តមានរបស់ព្រះជាម្ចាស់ពិសេស ព្រះជាម្ចាស់ប្រៀបបីដូចជាសមាជិកនៅក្នុងគ្រួសារ។ គ្រួសារនេះមិនមែនមានតែកូន៥នាក់ជាមួយឪពុកម្តាយ គឺមាន៨នាក់តែម្តងដោយសារព្រះជាម្ចាស់គឺជាសមាជិកនៅក្នុងគ្រួសារនេះ ពីព្រឹកដល់យប់វត្តមានរបស់ព្រះជាម្ចាស់គឺជាវត្តមានធម្មជាតិ មិននឹកឃើញនៅពេលគេវៃជួង មិននឹកឃើញថាថ្ងៃអាទិត្យយើងត្រូវការចូលអភិបូជា ប៉ុន្តែគេដឹងថាព្រះជាម្ចាស់គង់នៅនៅក្នុងក្រុមគ្រួសារនេះពីព្រឹកដល់យប់។ ហ្សេលីន ជាកូនស្រីរបស់ពួកគាត់ ធ្លាប់និយាយថា "**តាមពិតនៅក្នុងផ្ទះរបស់យើងបីដូចជាយើងរស់នៅជាប្រចាំថ្ងៃ គ្រប់ពេលវេលា គ្រប់ម៉ោង នៅក្នុងរបៀបអធិដ្ឋាន**" មិនមែនថាគេអធិដ្ឋានរហូតប៉ុន្តែគេដឹងថាព្រះជាម្ចាស់គង់នៅ។ គ្រប់សកម្មភាពដែលគេធ្វើដឹងថាព្រះជាម្ចាស់គង់នៅ អាចនិយាយថាគ្រួសារនេះរស់នៅក្នុងបរិយាកាសរបស់ព្រះជាម្ចាស់ បីដូចជាព្រះជាម្ចាស់ទៅជាដង្ហើមធម្មជាតិរបស់គេ ដូចជាមានខ្យល់ធម្មជាតិ ដូចជាមានអ៊ុកស៊ីសែនធម្មជាតិដែលចូលមកនៅក្នុងសួតរបស់យើងដើម្បីរស់នៅ។ ដូចព្រះនាងម៉ារីរស់នៅក្នុងបរិយាកាសរបស់ព្រះជាម្ចាស់នៅពេលគាត់ធ្វើដំណើរប្រាំពីរថ្ងៃដើម្បីទៅសួរសុខទុក្ខយាយអេលីហ្សាប៊ែត ព្រះនាងម៉ារីអធិដ្ឋានតាំងពីព្រឹកដល់ល្ងាច នឹកឃើញទំនុកតម្កើងដែលគាត់ស្គាល់នៅក្នុងសម្ពន្ធមេត្រីចាស់ ពេលទៅដល់ជួបយាយអេលីហ្សាប៊ែតហើយ គាត់លើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់របស់ព្រះនាងម៉ារីភ្លាម ដោយបញ្ចូលពាក្យអធិដ្ឋានដែលមកពីពាក្យក្នុងទំនុកតម្កើង និងពាក្យក្នុងដួងចិត្តរបស់គាត់ ដោយសារព្រះនាងម៉ារីដូចគ្រួសារដ៏វិសុទ្ធនេះរស់នៅក្នុងបរិយាកាសរបស់ព្រះជាម្ចាស់។

នៅក្នុងអត្ថបទទី២ "**ព្រះជាម្ចាស់ត្រូវតែវិនិច្ឆ័យយើង បងប្អូនសូមចូលមកជិតព្រះជាម្ចាស់ដែលវិនិច្ឆ័យមនុស្សទាំងអស់**" នៅសម័យសន្ត លូវីស និងសន្តី ហ្សេលី មានន័យថា១២០ឆ្នាំមុន ព្រះសហគមន៍ខ្លាចព្រះជាម្ចាស់ គ្រីស្តបរិស័ទភ័យខ្លាច គេគិតថាព្រះជាម្ចាស់ជាព្រះជាម្ចាស់ដែលវិនិច្ឆ័យយើង កាត់ក្តីយើង ដូចចៅក្រមអាចណែនាំឲ្យយើងចូលស្ថានបរមសុខឬចូលក្នុងស្ថាននរក។ គេមិនហ៊ានទទួលព្រះកាយព្រះគ្រីស្តរាល់ថ្ងៃទេ គេទទួលព្រះកាយព្រះគ្រីស្តតែពេលបុណ្យធំៗតែប៉ុណ្ណឹង ប៉ុន្តែក្រុមគ្រួសាររបស់សន្ត លូវីស និងសន្តី ហ្សេលី គេមិនភ័យខ្លាចព្រះជាម្ចាស់ គេដឹងថាយើងធ្វើដូចម្តេចដើម្បីខ្លាចព្រះជាម្ចាស់ ដោយដឹងថាព្រះជាម្ចាស់បានចាប់កំណើតជា

មនុស្ស នៅក្នុងភូមិបេថ្លេហឹមជាទារកមួយរូប។ លូវីស ធ្លាប់និយាយអំពីបុណ្យព្រះយេស៊ូប្រសូត ទៅកូនគាត់ថា "**នៅពេលយើងមើលឃើញព្រះជាម្ចាស់ ដែលចាប់កំណើតជាទារកមួយរូប យើងត្រូវតែស្រឡាញ់ព្រះជាម្ចាស់មែនទែន មិនគួរឲ្យភ័យខ្លាចពេលយើងនឹកឃើញដល់ព្រះជាម្ចាស់ ព្រះជាម្ចាស់ជាព្រះបិតាដ៏សប្បុរស ព្រះជាម្ចាស់ជាព្រះបិតាដែលស្រឡាញ់យើង ដែលលើកលែងទោសឲ្យយើង ដែលធ្វើដំណើរជាមួយយើង យើងមិនត្រូវភ័យខ្លាចព្រះអង្គទេ**"។ សន្តី តេរេសា ធ្លាប់និយាយថា "**ប្រសិនបើខ្ញុំធ្វើអំពើបាបធំជាងគេដែលអាចធ្វើបាននៅលើផែនដីនេះ ខ្ញុំដឹងថាព្រះជាម្ចាស់នៅតែស្រឡាញ់ខ្ញុំទៀត ហើយប្រសិនបើខ្ញុំទទួលស្គាល់អំពើបាបហ្នឹង ខ្ញុំដឹងថាព្រះជាម្ចាស់លើកលែងទោសឲ្យខ្ញុំ**" ដោយសារសន្តីតេរេសាមានបទពិសោធន៍មកពីឪពុកម្ដាយគាត់។ នៅពេលគាត់ធ្វើខុស ម្ដាយស្ដីឲ្យនិងក្រោយមកកូនស្រីតេរេសាសុំទោសម៉ែ កូនបានធ្វើខុស នៅពេលនោះម្ដាយបានស្វាគមន៍កូន ថើបកូននិងឲ្យស្ករគ្រាប់សូកូឡាទៀត។ នៅពេលកូនទទួលស្គាល់អំពីកំហុសរបស់ខ្លួន សូមលើកលែងទោសឲ្យគាត់ ទទួលស្វាគមន៍គាត់ ដើម្បីមានបទពិសោធន៍អំពីសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់។

ហ្សីលី គាត់ដឹងថា៦ខែទៀតត្រូវតែស្លាប់ ដោយសារនៅឆ្នាំ១៩៧៦មុនបុណ្យព្រះយេស៊ូប្រសូតគាត់មានជំងឺមហារីកសុដន់ ពេទ្យថាអត់មានថ្នាំព្យាបាលទេ។ ដូច្នេះ ៦ខែចុងក្រោយនៃជីវិតរបស់គាត់ គាត់ដូចជាត្រៀមខ្លួនដើម្បីជួបជាមួយព្រះជាម្ចាស់ ដើម្បីថែរក្សាគ្រួសារគាត់ចុងក្រោយ ទោះបីត្រូវតែស្លាប់គាត់ដឹងថាព្រះជាម្ចាស់ថែរក្សាគាត់ ព្រះជាម្ចាស់នឹងថែរក្សាក្រុមគ្រួសារគាត់នៅពេលគាត់ស្លាប់ហើយ។ គាត់គិតដូចនេះ "**ប្រសិនបើព្រះជាម្ចាស់អាចធ្វើការអស្ចារ្យមួយសម្រាប់ខ្ញុំម្យ៉ាងដែរ ប៉ុន្តែខ្ញុំលះបង់ចោលអ្វីៗទាំងអស់នៅព្រះហស្ដរបស់ព្រះអង្គ និងខ្ញុំសូមផ្ញើគ្រួសារដ៏ជាទីស្រឡាញ់របស់ខ្ញុំប្ដីនិងកូនស្រីទាំង៥នាក់ ជាពិសេសកូនស្រីតេរេសាអាយុទើបតែ៤ឆ្នាំនៅក្នុងព្រះហស្ដរបស់ព្រះជាម្ចាស់ ដើម្បីថែរក្សានិងស្រឡាញ់តទៅទៀត**"។ នៅពេលនោះយើងឃើញ ព្រះជាម្ចាស់ជាព្រះជាម្ចាស់ដែលពោរពេញដោយសេចក្ដីស្រឡាញ់ ប៉ុន្តែមិនមែនតែសេចក្ដីស្រឡាញ់ដែលជាទស្សនៈមួយ សេចក្ដីស្រឡាញ់ដែលគេទទួលយ៉ាងជាក់ស្ដែងនៅក្នុងបទពិសោធន៍នៃជីវិតរបស់គេជាប្រចាំថ្ងៃ។ សម្រាប់ លូវីស ក៏ដូចគ្នាដែរនៅពេលគាត់ចាស់ហើយគាត់ចាប់ផ្ដើមវង្វេងស្មារតីម្ដងៗ នៅពេលគាត់ដឹងខ្លួនគាត់និយាយទៅកូនគាត់ថា "**កូនអើយ! កុំព្រួយបារម្ភអំពីប៉ា ដោយសារប៉ាជាមិត្តសម្លាញ់របស់ព្រះជាម្ចាស់ ដូច្នេះមិនត្រូវព្រួយបារម្ភអ្វីសោះ**" ពិតមែនសន្ត លូវីស និងសន្តី ហ្សីលី បង្ហាញដល់យើងអំពីសេចក្ដីស្រឡាញ់ធម៌មេត្តាករុណារបស់ព្រះជាម្ចាស់។ យើងអាចនិយាយថា ព្រះជាម្ចាស់ជាសេចក្ដីស្រឡាញ់ ប៉ុន្តែសេចក្ដីស្រឡាញ់របស់ព្រះអង្គគង់នៅជាមួយយើង ហើយពេលយើងស្ដាប់រឿងជីវិតរបស់សន្ត លូវីស និងសន្តី ហ្សីលី

យើងមើលឃើញយ៉ាងជាក់ស្តែងព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់ គឺសេចក្តីស្រឡាញ់ដែលគង់នៅជាមួយយើងនៅពេលនេះ។ អាម៉ែន។